អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Chambres extraordinaires au sein
des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Royaume du Cambodge**
**Nation Religion Roi**

# សេចក្តីប្រកាសព័ត៌មាន

## សហចៅក្រមស៊ើបអង្កេត ឆ្លើយតបចំពោះសំណើសុំឲ្យមានកិច្ចស៊ើបសួរ របស់ក្រុមមេធាវីការពារក្តីមួយចំនួន លើការចោទប្រកាន់អំពីអំពើពុករលួយ នៅ អ.វ.ត.ក

ឆ្លើយតបចំពោះពាក្យសុំធ្វើឡើងដោយមេធាវីរបស់ នួន ជា ថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០០៩ (គាំទ្រដោយមេធាវីការពារក្តីពីរក្រុមផ្សេងទៀត) សហចៅក្រមស៊ើបអង្កេត នៅថ្ងៃនេះ បានចេញដីកាមួយ ដែលតាមរយៈដីកានេះ សហចៅក្រម បញ្ជាក់ថាខ្លួនមិនមានសមត្ថកិច្ចដើម្បីស៊ើបអង្កេតលើការចោទប្រកាន់ អំពីអំពើពុករលួយនៅ អ.វ.ត.ក។

ដោយធ្វើការគូសបញ្ជាក់ឡើងវិញពីការយកចិត្តទុកដាក់របស់ខ្លួនចំពោះតុលាការមួយដែលល្អឥតខ្ចោះ សហចៅក្រម សូមរំលឹកថា លក្ខខណ្ឌដំបូងដើម្បីឲ្យមានការកាត់ក្តីដោយយុត្តិធម៌នោះ គឺ ចៅក្រមខ្លួនឯងត្រូវតែគោរពច្បាប់ ក៏ដូចជាព្រំដែនកំណត់នៃសមត្ថកិច្ចដែលមានចែងនៅក្នុងអត្ថបទច្បាប់ជាមូលដ្ឋាន។ ហេតុដូច្នេះ យោងតាមច្បាប់ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ និងវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេត មិនឃើញមានសមត្ថកិច្ចទាល់តែសោះក្នុងការបំពេញកិច្ចដែលបានស្នើសុំដោយមេធាវីការពារក្តី។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

សហព្រះរាជអាជ្ញា បានបញ្ជូនមកសហចៅក្រមស៊ើបអង្កេត នូវកិច្ចការដែលលំបាក ប៉ុន្តែមានសារៈសំខាន់ គឺស្នើឲ្យស៊ើបអង្កេតពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ កិច្ចការដែលសំខាន់ផងដែរ គឺការធានាកេរ្តិ៍ឈ្មោះរបស់អង្គជំនុំជម្រះ និងការផ្តល់ចំណាត់ការសមស្របចំពោះការចោទប្រកាន់អំពីអំពើពុករលួយ ដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈនោះ មិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់សហចៅក្រមស៊ើបអង្កេតទេ ប៉ុន្តែជាសមត្ថកិច្ចរបស់អាជ្ញាធរកម្ពុជា និងអង្គការសហប្រជាជាតិ។

ចំពោះសំណើសុំរបស់មេធាវីការពារក្តីឲ្យមានការស៊ើបអង្កេតរដ្ឋបាលមួយលើការចោទប្រកាន់ទាំងនេះ សហចៅក្រម បានកត់សំគាល់ឃើញថា បញ្ហានេះត្រូវបានលើកឡើងរួចហើយជាមួយអាជ្ញាធរមានសមត្ថកិច្ចកម្ពុជា និងអង្គការសហប្រជាជាតិ និងសម្រេចថា នឹងផ្ញើជូនអាជ្ញាធរទាំងនេះ នូវដីកាថតចម្លងមួយច្បាប់។

ដើម្បីឲ្យមានតម្លាភាព សហចៅក្រមស៊ើបអង្កេត បានសម្រេចផ្សព្វផ្សាយដីការបស់ខ្លួន រួមទាំងសំណើសុំនិងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី។ ឯកសារដែលមិនត្រូវបានផ្សព្វផ្សាយ គឺឯកសារមួយចំនួនដែលភ្ជាប់ជាឧបសម្ព័ន្ធនឹងសំណើសុំ ដែលជាកម្មវត្ថុនៃនីតិវិធីតុលាការ ឬរដ្ឋបាលដាច់ដោយឡែក។ ឯកសារទាំងមូល នឹងអាចមើលបានដោយចុចលើ៖

http://www.eccc.gov.kh/khmer/court_doc.list.aspx?courtDocCat=case_docs

រួចចូលក្នុងប្រអប់ "រុករកឯកសារ លេខ" ហើយវាយលេខកូដរបស់វា "D158"។

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០០៩



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.